# ថ្នាក់ដឹកនាំ និងមន្រ្តីជំនាញក្រសួងពាណិជ្ជកម្ម ជួបពិភាក្សាការងារជាមួយគណៈកម្មការទី៩ នៃរដ្ឋសភា

ក្នុងឱកាសនៃវិស្សមកាលរបស់រដ្ឋសភាជាតិ ចាប់ពីខែកក្កដា ដល់ខែកញ្ញា នាឆ្នាំ២០១០នេះ គណៈកម្មការទី៩នៃរដ្ឋសភា ទទួលបន្ទុកផ្នែកសាធារណៈការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគូរូបនីយកម្ម និងសំណង់ ដឹកនាំដោយលោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានអញ្ជើញមកពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ដឹកនាំដោយ ដោយឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម នារសៀលថ្ងៃទី០៣ ខែ សីហា ឆ្នាំ២០១០ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។





លោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានជម្រាបជូន ពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បីសិក្សាស្វែងយល់ពីសកម្មភាព និងសមិទ្ធិផលការងារសំខាន់ៗ ដែលក្រសួងពាណិជ្ជកម្មសម្រេចបានកន្លងមក និងទិសដៅអនុវត្តបន្តពិសេសស្វែងយល់ពីប្រសិទ្ធិភាពនៃការប្រតិបត្តិច្បាប់នានា ដែលរដ្ឋសភាបានអនុម័តរួចហើយ មានដូចជា: ច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម-ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់-ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីការ គ្រប់គ្រងគុណភាព សុវត្ថិភាព ផលិតផល ទំនិញ និងសេវា-ពិធីសារ និងកិច្ចព្រមព្រៀងនានារបស់កម្ពុជា នៅក្នុងអង្គការពាណិជ្ជកម្ម ពិភពលោក (WTO) ព្រមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិផ្សេងៗទៀត ។

បន្ទាប់ពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានមានប្រសាសន៍សំដែងការស្វាគមន៍ រួចមក តំណាងអគ្គនាយកដ្ឋាន និងនាយកដ្ឋានជំនាញ ដែលមានការពាក់ព័ន្ធ បានធ្វើបទឧទ្ទេសជាបន្តបន្ទាប់ ស្តីពីលទ្ធផលការងារនិងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ពាណិជ្ជកម្មនានា ដែលរដ្ឋសភាបានអនុម័តរួចហើយ ព្រមទាំងលើកឡើងពីទិសដៅអនុវត្តបន្តផងដែរ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីការខិតខំរបស់ក្រសួងពាណិជ្ជកម្ម ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំអនុវត្តគោលនយោបាយពាណិជ្ជកម្មជាតិ និងអន្តរជាតិ ធ្វើឱ្យវិស័យពាណិជ្ជកម្ម ដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្នុងប្រទេស ពិសេសកម្ពុជាបានធ្វើសមាហរណកម្មពាណិជ្ជកម្មរបស់ខ្លួនក្នុងតំបន់និងពិភពលោក និងបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងពិធីសារជាច្រើនជាមួយប្រទេសជាដៃគូរ ដែលធ្វើឱ្យកម្ពុជា មានគោលនយោបាយពាណិជ្ជកម្មស្របតាមនិយាមអន្តរជាតិ និងទទួលភាពអនុគ្រោះពាណិជ្ជកម្ម ពីប្រទេសអភិវឌ្ឍន៍ និងប្រទេសដៃគូរជាច្រើន ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានវាយតំលៃខ្ពស់ចំពោះគណៈកម្មការទី០៩នៃរដ្ឋសភា ដែលបានសហការយ៉ាងល្អជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការចូលរួមតាក់តែងច្បាប់ និងអនុម័តច្បាប់ពាណិជ្ជកម្មនានា ស្របពេលដែលកម្ពុជាមានការចាំបាច់ជាច្រើនក្នុងការធ្វើច្បាប់ពាណិជ្ជកម្មឱ្យស្របតាមគោលការណ៍ នៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

លោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានថ្លែងអំណរគុណ និងវាយតំលៃខ្ពស់ ចំពោះសកម្មភាពការងាររបស់ក្រសួងពាណិជ្ជកម្ម ក្រោមការដឹកនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ដែលបានសម្រេចកិច្ចការយ៉ាងធំធេងជូនជាតិ និងប្រជាជន ពិសេសគឺការចរចារយ៉ាងស្វិតស្វាញ ដើម្បីធ្វើឱ្យវិស័យពាណិជ្ជកម្មកម្ពុជា បានធ្វើសមាហរណកម្ម ក្នុងតំបន់និង

ពិភពលោកប្រកបដោយជោគជ័យ ។ ជាមួយគ្នានេះ លោកជំទាវ បានធ្វើការកោតសរសើរផងដែរ ចំពោះប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ពាណិជ្ជកម្មនានា ដែលសភាបានអនុម័តរួចហើយ បើទោះបីមិនទាន់បានល្អទាំងអស់ តែក្រសួងបានខិតខំយ៉ាងខ្លាំង តាមរយៈការកែទំរង់ជាបន្តបន្ទាប់ ព្រមទាំងបង្ហាញនូវទិសដៅអនុវត្តបន្ត ដែលអាចប៉ាន់ប្រមាណបាន ។

លោកជំទាវប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានសន្យាគាំទ្រសំណើររបស់ក្រសួងពាណិជ្ជកម្ម ដែលចង់បានការបញ្ជាក់ពីគណៈកម្មការអចិន្ត្រៃយ៍នៃរដ្ឋសភា ថាតើកិច្ចព្រមព្រៀង វីពីធីសារណាខ្លះ? ដែលត្រូវឆ្លងការអនុម័តពីរដ្ឋសភា និងគំនិតផ្តួចផ្តើមធ្វើយ៉ាងណាឱ្យច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា បានដាក់ចូលក្នុងកម្មវិធីសិក្សានៃក្រសួងអប់រំឱ្យបានទូលំទូលាយ ។